

# ជំងឺ COVID-19
# ការពិតនៃថ្នាំបង្ការ

## ថ្នាំបង្ការទាំងឡាយការពារប្រឆាំងនឹងការទទួលបានលទ្ធផលដ៏មិនល្អបំផុត ដោយសារជំងឺ COVID-19។



- ថ្នាំបង្ការជំងឺ COVID-19 កាត់បន្ថយហានិភ័យរបស់អ្នកក្នុងការធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ ដោយសារជំងឺ COVID-19 ការត្រូវសម្រាកព្យាបាលនៅមន្ទីរពេទ្យ ឬការស្លាប់ផងដែរ។ ថ្នាំបង្ការក៏ជួយកាត់បន្ថយហានិភ័យរបស់អ្នកក្នុងការកើតមានជំងឺ COVID រយៈពេលវែងផងដែរ។
- ថ្នាំបង្ការជំងឺ COVID-19 ប្រភេទ Pfizer ប្រភេទ Moderna និងប្រភេទ Novavax ត្រូវបាន **ធ្វើឱ្យថ្មីឡើងវិញ** ដើម្បីការពារប្រឆាំងនឹងពូជមេរោគដែលកើតមានថ្មីៗនេះ។
- ថ្នាំបង្ការដែលបានធ្វើឱ្យថ្មីឡើងវិញនេះអាចបង្កើនប្រព័ន្ធការពារពីពេលមុនមក (ពីការចាក់ថ្នាំបង្ការ ឬការឆ្លងមេរោគពីពេលកន្លងមក) ដែលអាចនឹងចុះអន់ថយទៅតាមពេលវេលា។




**មនុស្សគ្រប់រូបដែលមានអាយុចាប់ពី 6 ខែឡើងទៅ គួរតែទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 ដែលបានធ្វើឱ្យថ្មីឡើងវិញ (updated COVID-19 vaccine) នេះ។**



- **មនុស្សគ្រប់រូបដែលមានអាយុចាប់ពី 5 ឆ្នាំឡើងទៅ** គួរតែទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 ដែលបានធ្វើឱ្យថ្មីឡើងវិញចំនួនមួយដូស នារដូវស្លឹកឈើជ្រុះនេះ។
- **កុមារទាំងឡាយដែលមានអាយុចាប់ពី 6 ខែ ទៅ 5 ឆ្នាំ** គួរតែមានការពិភាក្សាជាមួយនឹងអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់ពួកគេអំពីចំនួនដូសថ្នាំបង្ការដែលពួកគេត្រូវការទទួលចាក់។ ចំនួននេះគឺអាស្រ័យទៅលើចំនួនដូសថ្នាំបង្ការដែលពួកគេបានទទួលចាក់នាឆ្នាំមុនៗ។
- **អ្នកដែលមានប្រព័ន្ធភាពសុំាចុះខ្សោយ** អាចនឹងត្រូវការទទួលចាក់ដូសថ្នាំបង្ការដែលបានធ្វើឱ្យថ្មីឡើងវិញបន្ថែមទៀត។ ចូរពិភាក្សាជាមួយនឹងគ្រូពេទ្យរបស់អ្នកអំពីកាលវិភាគនៃការចាក់ថ្នាំបង្ការដែលល្អបំផុតសម្រាប់អ្នក។
- **មនុស្សពេញវ័យដែលមានអាយុចាប់ពី 65** ឆ្នាំឡើងទៅគួរតែទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 ដែលបានធ្វើឱ្យថ្មីឡើងវិញចំនួនមួយដូសបន្ថែមទៀត ក្នុងរយៈពេលយ៉ាងហោចណាស់ 4 ខែ បន្ទាប់ពីការចាក់ដូសពីពេលមុនរបស់ពួកគេ។
- មនុស្សគ្រប់រូបគួរតែទទួលចាក់ថ្នាំបង្ការ បើទោះបីជាពួកគេ **មានផ្ទៃពោះ ឬកំពុងបំបៅកូនដោយទឹកដោះ** ឬក៏ធ្លាប់មានជំងឺ COVID-19 រួចហើយក៏ដោយ។
- អ្នកដែលមានអាយុចាប់ពី 12 ឆ្នាំឡើងទៅ ហើយដែលមិនអាចទទួលចាក់ថ្នាំបង្ការប្រភេទ Pfizer ឬប្រភេទ Moderna បានទេនោះ អាចនឹងទទួលចាក់ថ្នាំបង្ការប្រភេទ Novavax ដែលបានធ្វើឱ្យថ្មីឡើងវិញ (updated Novavax vaccine) ក្នុងរយៈពេលយ៉ាងហោចណាស់ 2 ខែ បន្ទាប់ពីបានទទួលចាក់ថ្នាំបង្ការដូសចុងក្រោយបង្អស់របស់ពួកគេ។
- សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ cdc.gov/coronavirus/vaccine។

VaccinateLACounty.com

County of Los Angeles Public Health



# ជំងឺ COVID-19 ការពិតនៃថ្នាំបង្ការ

## ទីកន្លែងទទួលចាក់ថ្នាំបង្ការ

ប្រសិនបើអ្នកមានធានារ៉ាប់រង សូមទាក់ទងទៅកាន់អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់អ្នក ដើម្បីធ្វើការណាត់ជួបដើម្បីចាក់ថ្នាំបង្ការ។ ថ្នាំបង្ការក៏មានសម្រាប់ផ្តល់ជូនដល់អ្នកដែលមិនមានធានារ៉ាប់រងផងដែរ នៅតាមឱសថស្ថាន (កន្លែងលក់ថ្នាំពេទ្យ) និងមណ្ឌលសុខភាពជាច្រើននៅក្នុងសហគមន៍។ កំណត់សម្គាល់៖ អនីតិជន (ជនមិនទាន់គ្រប់អាយុ) ត្រូវការការអនុញ្ញាតពីឪពុកម្តាយ ឬអាណាព្យាបាលស្របច្បាប់ ដើម្បីទទួលចាក់ថ្នាំបង្ការ។



ដើម្បីស្វែងរកទីតាំងមួយដែលនៅជិតអ្នក៖ សូមចូលទៅកាន់គេហទំព័រ៖ http://publichealth.lacounty.gov/vaccines/ ឬក៏ទូរស័ព្ទទៅកាន់លេខ **1-833-540-0473** ឬលេខ **2-1-1**។

ការចាក់ថ្នាំបង្ការនៅតាមផ្ទះគឺអាចរកបាន ហើយអាចស្នើសុំបានតាមរយៈការទូរស័ព្ទទៅកាន់លេខ **1-833-540-0473** ឬក៏ការចូលទៅកាន់គេហទំព័រ VaccinateLACounty.com ហើយចុចនៅលើផ្នែក In-Home Vaccines (ការចាក់ថ្នាំបង្ការនៅតាមផ្ទះ)។

## ផលប៉ះពាល់កម្រិតធ្ងន់ធ្ងរគឺកម្រនឹងកើតមាន។



- ផលប៉ះពាល់ទូទៅរួមមាន ការឈឺ ឡើងហើម ឬឡើងក្រហមនៅនឹងកន្លែងដែលបានចាក់ថ្នាំបង្ការនោះ ឈឺតាមសន្លាក់ឬឈឺសាច់ដុំ ហើមកូនកណ្តុរ គ្រុនក្តៅ គ្រុនរងា ឈឺក្បាល និងមានអារម្មណ៍អស់កម្លាំង។ ផលប៉ះពាល់ចំពោះកុមារតូចៗរួមមានដូចជា ឆាប់យំ ឆាប់ខឹង ងងុយគេង និងបាត់បង់ចំណង់អាហារ ជាដើម។
- ផលប៉ះពាល់ទាំងឡាយគឺជាសញ្ញាដែលបង្ហាញថាប្រព័ន្ធភាពស៊ាំរបស់អ្នកកំពុងតែ**បង្កើតប្រព័ន្ធការពារ**។ ផលប៉ះពាល់ទាំងនេះអាចនឹងរំខានដល់អ្នកក្នុងការធ្វើសកម្មភាពប្រចាំថ្ងៃមួយចំនួន ប៉ុន្តែគួរតែនឹងបាត់ទៅវិញក្នុងរយៈពេលមួយ ឬពីរថ្ងៃ បន្ទាប់ពីបានចាក់ថ្នាំបង្ការរួច។
- ផលប៉ះពាល់បែបធ្ងន់ធ្ងរគឺកម្រនឹងកើតមាន។

## ថ្នាំបង្ការជំងឺ COVID-19 គឺមានសុវត្ថិភាព និងមានប្រសិទ្ធិភាព។





- អ្នកមិនអាចកើតជំងឺ COVID-19 ដោយសារថ្នាំបង្ការនោះទេ។ មិនមានថ្នាំបង្ការប្រភេទណាមួយមានផ្ទុកមេរោគដែលអាចបណ្តាលឱ្យកើតជំងឺ COVID-19 ឡើយ។
- ថ្នាំបង្ការទាំងឡាយត្រូវបានសាកល្បងទៅលើមនុស្សរាប់ម៉ឺននាក់ រួមទាំងមនុស្សដែលមានពណ៌សម្បុរផ្សេងគ្នា មនុស្សវ័យចំណាស់ និងមនុស្សដែលមានបញ្ហាសុខភាពប្រចាំកាយផងដែរ ហើយបានរកឃើញថា **មានសុវត្ថិភាព និងមានប្រសិទ្ធិភាព**។
- ចាប់តាំងពីខែធ្នូ ឆ្នាំ 2020 មក **មនុស្សរាប់រយលាននាក់** បានទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 ដោយសុវត្ថិភាព។
- ថ្នាំបង្ការជំងឺ COVID-19 នៅតែបន្តឆ្លងកាត់ **ការត្រួតពិនិត្យផ្នែកសុវត្ថិភាពយ៉ាងល្អិតល្អន់បំផុត** ក្នុងប្រវត្តិសាស្ត្រសហរដ្ឋអាមេរិក។
- មិនមានភស្តុតាងណាមួយដែលបង្ហាញថាថ្នាំបង្ការជំងឺ COVID-19 បណ្តាលឱ្យមានបញ្ហាមិនអាចមានកូននោះទេ។ ថ្នាំបង្ការទាំងនេះមានសុវត្ថិភាពសម្រាប់អ្នកដែលមានផ្ទៃពោះ និងត្រូវបានណែនាំដោយអ្នកឯកទេសផ្នែកផ្ទៃពោះផងដែរ។